ខ្ញុំក៏អត់យល់ដែរថា បើគ្រាន់តែយើងមិនស្រឡាញ់មនុស្សដែលយើងរាប់អាន ហើយព្យាយាមនិយាយគ្នាឱ្យមានព្រំដែនច្បាស់លាស់រវាងស្នេហានិងមិត្តភាព ម្តេចគេចាំមានការឈឺចាប់ជ្រៅនិងចាត់ទុកថាការបដិសេធនោះជារឿងមាក់ងាយឈានដល់គេចមុខលែងរាប់អានគ្នាបាន?

រឿងនេះជាអតីតកាលមួយកាលនៅវិទ្យាល័យថ្នាក់ទី១០។ ខ្ញុំនិងVan។ តាមពិតគេឈ្មោះពេញថា វណ្ណា តែមិត្តជិតដិតគ្រប់គ្នាហៅថា វណ្ណ ម្ល៉ោះហើយគេដាក់ឈ្មោះខ្លួនឯងលើបណ្តាញសង្គមកាត់ខ្លីថា VAN។

Van ជាប្រុសស្អាត សម្បុរស ខ្ពស់ និងមានកែវភ្នែកមុត ច្រមុះស្រួច សំឡេងធំច្បាស់រហ័សរហួនហើយគេពូកែគណិតវិទ្យាជាងអ្នកណាទាំងអស់ក្នុងថ្នាក់។

ជារឿងធម្មតារបស់ខ្ញុំដែលចូលចិត្តមិត្តភក្តិជាសិស្សពូកែ និងមានកាយសម្បទាដូចរបៀបគេ។ គ្នាយើង៥នាក់ ក្រោយមកប្តូរសាលាអស់ម្នាក់សល់តែ៤នាក់គឺ ឡែន រាជ Van និងខ្ញុំ។

តាំងពីថ្នាក់ទី៨មកស្គាល់គ្នាជាលក្ខណៈក្រុមល្បីដែលប៉ះគ្នាពេលណាបែកអូរហូរស្ទឹងដូចឆ្កួតវង្វេង តែបើគ្រូហៅទៅឈរលើក្តារខៀនក៏ទៅជាក្រុម ព្រោះសកម្មភាពមិនដែលប្រព្រឹត្តឡើងដោយឯកោទេ។

ពេលវេលាកន្លងហួសកាលណា ស្នេហាជាវិញ្ញាសារថ្មី។

អ្នកណាមិនចង់បានស្នេហា?

តែពិតណាស់ថា មិនចង់បានឡើយក្នុងចំណោមមនុស្សធ្លាប់វាយក្បាលគ្នា។

«រាជលួចប្រាប់មកថា Van ចង់ទិញកាដូឱ្យអ្ហែងValentineហ្នឹង!»

អាឡែនមកនិយាយប្រាប់ខ្ញុំដោយស្រពោន។ ខ្ញុំមិនមែនមិនដឹងថា ចុងក្រោយនេះ Van ធ្វើចរិតប្លែកៗទេ។

នៅសាលាយើង សិស្សៗនិយមហៅមិត្តជិតដិត Bestie ខ្លះហៅ ថា BFF ខ្លះហៅថា "Bro" ប៉ុន្តែខ្ញុំហៅគេថា ក្វាន់ (Kvan)។ ទោះជាយ៉ាងណា ខ្ញុំមិនដឹងចិត្តទាំងអស់គ្នាដូចខ្ញុំដែរអត់ ដែលចង់មានមិត្តល្អបំផុតម្នាក់និងជារៀងរហូតទៅ។

ពាក្យថាមិត្តល្អបំផុតរបស់យើង គឺអ្នកដែលយើងអាចនិយាយ អាចចែករំលែកអាចបញ្ចេញកំហឹង អំពីអ្វីគ្រប់យ៉ាងដែលមិនអាចឱ្យអ្នកផ្សេងដឹង។

«ហ្នាថាយក?»

ខ្ញុំតបដោយលបលួចសម្គាល់ឃើញទឹកមុខអាឡៃន។ ការសង្ស័យខ្ញុំមិនខុសទេ។ មានអ្នកចង់បានកាដូរបស់ Van តែ Kvanបែរជាចង់ជូនខុសមនុស្ស។

«មែន?»

ឡៃនសួរបញ្ជាក់ដោយតាមសម្លឹងរកការពិតក្នុងជម្រៅចិត្តខ្ញុំ។ ខ្ញុំបានប្រាប់មិត្តវិញឱ្យនាងស្រាលសេចក្តីទុក្ខសោកព្រោះលបស្នេហ៍Van៖

«មានខ្សែចំណងដែលមើលមិនឃើញមួយ ចងយើងទាំងបួនឱ្យក្លាយជាមិត្តល្អបំផុតនឹងគ្នា! ចំណងនិស្ស័យនេះមានតម្លៃណាស់ យើងមិនផ្តាច់វាទេឯងត្រូវដឹង! មួយទៀត ទោះបីជាពួកយើងជាមិត្តល្អបំផុតក៏ដោយ ក៏យើងនៅតែមិនផ្លោះផុតចំណងនោះបានដែរ អានេះចិត្តយើង! គ្រប់គ្នាត្រឹមជាមិត្ត! បន្ទាត់ស្នេហានៅមិនទាន់ចង់គូស ហើយបើទៅថ្ងៃមុខមានមែន ក៏ត្រូវបម្រុងទុកសម្រាប់តែមនុស្សដែលយើងស្រឡាញ់! មិនមែនមិត្តល្អៗរបស់យើងសព្វថ្ងៃនេះទេ!»

«ឯងឈែតពាក្យនេះមក វណ្ណារី! យើងចង់ឱ្យទៅរាជ ឱ្យគេ Forward ទៅឱ្យVan!» ឡៃននិយាយមែនទែន មិនមែនលេងសើចដូចរាល់ដងទេ។

ប៉ុន្តែខ្ញុំបដិសេធ។

«ចាំយើងនិយាយប្រាប់ Van ខ្លួនយើង!»

រនាំងមួយលេចចេញមក ពេលមិត្តល្អបំផុតម្នាក់បង្ហាញច្បាស់ឡើងៗថា កំពុងលង់ស្រឡាញ់ខ្ញុំដែលការធ្វើមិនដឹងរឿងមិនមែនជាគំនិតល្អទេ។ ការគេចៗក៏បានការត្រឹមតែ

បណ្តោះអាសន្នក្រោយមកពិតជារំខានចិត្តណាស់ ប្រសិនមិនរកពេលនិយាយគ្នាឱ្យច្បាស់។

Van ឆាតមករញ៉េររញ៉ៃយប់ៗឡើង រកធ្វើកិច្ចការសាលាមិនកើតចំណែកថា ព្រឹកឡើងភ្លាមក៏ឃើញមុខនៅជណ្តើរផ្ទះទៀត។

ភាគច្រើនយើងគិតថាឃើញបែបនេះ មានតែនៅក្នុងរឿងភាគ? ប៉ុន្តែ...ហេសហេ រឿងដ៏ទើសទាល់មួយនេះបាននឹងកំពុងកើតឡើងនៅក្នុងជីវិតពិតរបស់ខ្ញុំពេលនេះតែម្តង។ តែក៏មិនមែនជារឿងត្រូវរអ្អួតអាងអ្វីឡើយ ដ្បិតអីវាគ្មានអនាគតអីទេ សម្រាប់ដែលមនុស្សយើងរាប់ជាមិត្ត ចង់ឈានទៅដល់រឿងប្តូរជីវិតរួមរស់នឹងគ្នា។

«Van ឯងកុំមកទទួលខ្ញុំទៀត ខ្ញុំឱ្យប្អូនជីដូនមួយខ្ញុំមកដឹកហើយ!»

«ថ្នាក់ជាមួយក្នាសោះ ទៅជាមួយគ្នាមិនបាន?!»

«Van ឯងកុំសាំ ខ្ញុំថាម៉េចក៏អ៊ីចឹងទៅ!»

«ខ្លាចសង្សារឃើញហ្មែន» Vanសួរខ្ញុំដូចអន់ចិត្ត។ គេនិយាយលើកនេះ គឺហ៊ានបង្ហាញភាពច្រណែនចេញមកពេញទំហឹង ដូចជាកំពុងប្រចណ្ឌខ្ញុំជាមួយពួកកូនចិនប្រុសៗជាអ្នកជិតខាងដែលតែងដកកមើលមកខ្ញុំរហង់ពេលដើរទៅរៀនម្តងៗ។

«ឬមួយម៉ាក់វណ្ណារីឯងលើកឱ្យមានគូដណ្តឹង?»

គេថាមកទៀតមុខក្រញូវៗ។ គិតថា ខ្ញុំមិនចេះខឹងដែរមែន?

ខ្ញុំខឹងបកVan វិញ។ ណាមួយចិត្តសែនទើសទាល់នឹងVan ក៏និយាយទាំងក្រញូវដូចគ្នា៖

«Vanឯង តិចខ្ញុំឈប់និយាយរកណ៎ា!»

ត្រឹមពាក្យប៉ុណ្ណឹងខ្ញុំដើររ៉ុយមកសាលាចោលគេ។ លើកនេះ Van លែងជិះម៉ូតូត្រឹកៗតាមខ្ញុំទៀតហើយ។ គេម៉ឺងម៉ូតូបោលថែមល្បឿនចាកចេញទៅឆ្ងាយ។

ស្អែកឡើងគ្រាន់បើដែរលែងមានគេមកចាំក្រោមផ្ទះ។ ខ្ញុំធូរចិត្ត ថែមទាំងបាត់មិនឃើញ Van មកសាលាពីរបីថ្ងៃ។ នៅតែឡែននិងរាជដែលមិនចង់និយាយរកខ្ញុំ។ ខ្ញុំដឹងថា ពួកគេខឹងខ្ញុំរឿង Van តែខ្ញុំមិនទទួលថាខ្លួនឯងខុសទេ បើពួកយើងទាំងបួនបែកបាក់គ្នា ក៏ព្រោះ Van មិនចេះគិតសោះ។

រំលងមួយថ្ងៃទៀត ឡែនមកប្រាប់ថា Van ដូរទៅរៀននៅសាលាឆ្ងាយវិញ។ ខ្ញុំធ្វើដូចជាមិនចង់ដឹងមិនចង់ឮ តែចិត្តមួយក៏ស្តាយVan ចិត្តមួយខឹងថាម្តេចមានរឿងបែបនេះកើតមានលើពួកយើង។

ខ្ញុំរកVan ក្នុង Social តែមិនឃើញទេ។

ខ្ញុំលាន់មាត់ថា «ចរិតស្រី!» ហើយបំភ្លេចចោលធ្វើដូចមិនស្តាយVan តែតាមពិតខ្ញុំស្រងេះស្រងោចរឿងកន្លងមករវាងគ្នាយើងបួននាក់ណាស់។

ខ្ញុំសួររាជថា ហេតុអ្វីVan ចាំបាច់ធ្វើអ៊ីចឹង? រាជមិននិយាយ គេថាគេគ្មានយោបល់ គ្រប់គ្នាជាមិត្តគេមិនចង់បកស្រាយអ្នកណាខុសអ្នកណាត្រូវ។ ចំណែកឡែន ឡែនប្រាប់មក Van តូចចិត្ត និង

ឈឺចាប់ព្រោះខ្ញុំចង់បញ្ចប់រឿង។ ខ្ញុំបានបដិសេធភ្លាមថា Van រឹតតែឆ្កួត និងមិនគួរឱ្យចូលចិត្តឡើងដែលគិតបែបនេះបញ្ចប់អី ខ្ញុំនឹងគេមិនដែលចាប់ផ្តើមស្អីទាំងអស់ ខ្ញុំមានអារម្មណ៍ថា គេគ្មានមិត្តភាពស្មោះ ហើយខ្ញុំមិនសប្បាយចិត្តទេពេលរំឭកឡើងវិញពី Van។

សម្រាប់ខ្ញុំ ខ្ញុំតែងយល់ថាការបដិសេធអ្នកណាម្នាក់ មិនមែនមានន័យថា យើងមិនចូលចិត្តគេឬទុកគេមិនមានតម្លៃមិនល្អអ្វីនោះទេ វាគ្រាន់តែមានន័យថាយើងទាំងពីរមិនអាចទៅរួចជាមួយគ្នាឋានៈជាគូស្នេហ៍។

ច្រើនឆ្នាំក្រោយមកខ្ញុំនិងឡៃនៅតែទាក់ទងគ្នា ចំណែករាជបានរៀបការដោយមានសុភមង្គលហើយផ្លាស់ទៅរស់នៅខេត្តកំពត រកស៊ីជាម្ចាស់កសិដ្ឋានចិញ្ចឹមមាន់ធំមួយយ៉ាងជោគជ័យមានបាន។

១២ឆ្នាំបានកន្លងផុតយ៉ាងលឿន។

រឿងជាច្រើននៃជីវិតបានសាកល្បងយើង រុញយើងឱ្យលែងអាចជាយើង ដូចកាលពីមុនទៀត។

ខ្ញុំអាយុ២៨ឆ្នាំហើយ មិនទាន់រៀបការនិងមិនទាន់មានសង្សារណាម្នាក់ប្រាកដប្រជានៅឡើយ។ នេះជារឿងម្តាយខ្ញុំកើតខ្វល់ និងរករឿងស្ទើរគ្មានលោះថ្ងៃ។

ខ្ញុំធ្វើការនៅគ្រឹះស្ថានហិរញ្ញវត្ថុមួយ។ ការងារតែងតែជាសកម្មភាពប្រយុទ្ធឡើងទៅមុខជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ទៅតាមអាយុកាលនិងបទពិសោធរបស់ខ្ញុំ ដែលភាគច្រើនខ្ញុំទទួលជោគជ័យនិងទទួលបានតួនាទីគួរសមទាំងនៅក្នុងវ័យប៉ុណ្ណេះ។

ខ្ញុំមានកូនចៅ៨នាក់ ហើយមានមេកោយតែ២នាក់ដែលជាមេដឹកនាំកំពូល និងដែលយកចិត្តទុកដាក់ទុកខ្ញុំថា ជាបុគ្គលិកបង្គោល។

ជាមួយនឹងចំណូលដែលកើនឡើងរបស់ខ្ញុំ ព្រមទាំងគំនិតបណ្តាក់វិនិយោគទៅលើការទិញដីធ្លីព្រមទាំងការចូលគ្នាទិញអចលនវត្ថុសម្រាប់ជួលមួយចំនួនជាមួយសាច់ញាតិ បានធ្វើឲ្យខ្ញុំមានលក្ខខណ្ឌរស់នៅមិនព្រួយបារម្ភអំពីអនាគតនៃហិរញ្ញវត្ថុរបស់ខ្ញុំនោះទេ។

ការព្រួយបារម្ភដ៏សំខាន់ គឺថាខ្ញុំគ្មានបុរសណាម្នាក់ដែលស័ក្តិសមនឹងឲ្យខ្ញុំលង់ស្នេហ៍ទាល់តែសោះ។

ពេលខ្លះខ្ញុំមិនយល់ខ្លួនឯងថាហេតុអ្វីខ្ញុំមិនចេះស្រឡាញ់? ខ្ញុំមិនចេះរំភើប ឬក៏ចង់បាននរណាម្នាក់មកជាគូជីវិតនៅក្នុងចំណោមមនុស្សដែលខ្ញុំបានជួបនៅឡើយសោះ។

ក្នុងរយៈពេលដប់ពីរឆ្នាំមកនេះប្រុសៗមួយចំនួនបានមកដល់ ដូចលំនាំរបស់Van ពួកគេបង្ហាញខ្លួនមានទាំងអ្នករឹងមាំហួសហេតុ អ្នកមោទនភាពខ្លាំងពេក អ្នកឡូយអស្ចារ្យពេក ឬក៏អ្នកទន់ខ្សោយពេក សុទ្ធតែខ្ញុំមិនអាចទទួលយកបាន ហើយធុញទ្រាន់មួម៉ៅរាល់ពេលឃើញវត្តមានពួកគេ។

ការឆ្លើយតបទទឹងទទែងនេះបណ្ដាលឲ្យពួកគេចាកចេញទៅជាលំដាប់ ព្រោះតែចរិតព្រងើយកន្តើយរបស់ខ្ញុំ ដែលម្ដងម្កាលខ្ញុំក៏បានទិតៀនខ្លួនឯងនិងចង់ឲ្យខ្លួនឯងចេះទោរទន់ជាងនេះទៅបន្តិច ជាមនុស្សស្រីសាមញ្ញម្នាក់គិតអ្វីៗក្នុងរឿងទំនាក់ទំនងស្រីប្រុសហាក់ងាយៗជាងនេះ និងទទួលយកមនុស្សប្រុសសាមញ្ញធម្មតាបាន ដូចដែលអ្នកដទៃគេធ្លាប់ទទួលយក។

ខ្លះអាយតំណាលខ្ញុំ គេមានកូនពីរនាក់បាត់ទៅហើយតួយ៉ាងដូចជាឡែន អាទិត្យក្រោយនេះគឺឡែនចូលរោងការដែរហើយ។

អនាគតស្វាមីរបស់គេ គឺជាសាស្ត្រាចារ្យមួយរូបនៅសាកលវិទ្យាល័យ ហើយថែមទាំងមានតួនាទីបន្ថែមជាទីប្រឹក្សានៅក្រុមហ៊ុនឯកជនមួយទៀត។

ពួកគេមិនមែនជាអ្នករកស៊ី ប៉ុន្តែចំណេះដឹងរបស់ពួកគេនឹងដឹកនាំជីវិតរបស់ពួកគេទៅរកស្ថេរភាពដែលរស់នៅមិនលំបាកពេកទេ។

ឃើញថាពួកគេមានសុភមង្គល ខ្ញុំក៏សប្បាយចិត្តនិងជូនពរនាងនៅថ្ងៃដែលឡែនយកសំបុត្រអញ្ជើញមកដល់។

តាមពិតឡែនធ្លាប់បានស្រឡាញ់Van ក្រោយមកឡែនក៏បានជួបមនុស្សច្រើនទៀតក្នុងវិថីស្នេហារបស់នាង។ នាងជាមនុស្សស្រីមិនសូវពូកែក្នុងអាជីព មិនធ្វើអ្វីមួយបានលេចធ្លោក្នុងសង្គម តែអ្វីដែលខ្ញុំដឹងមកគឺឡែនមានជីវិតយុវវ័យរាក់ទាក់រួសរាយ មានមន្តស្នេហ៍និងភាពស្រស់ស្អាត មានស្នេហាឡូយឆាយច្រើន តែចុងក្រោយឡែនព្រមបញ្ចប់ជីវិតនៅលីវនេះជាមួយបុរសម្នាក់ចុងក្រោយគេ។ នេះជាមេរៀនមួយសម្រាប់យើង។ មិនថាមនុស្សយើងមានចរិតខុសគ្នា ខ្លះទុកជីវិតស្នេហាជាអាទិភាពនិងធ្វើវាយ៉ាងសកម្មកាលនៅជាយុវវ័យ និងមានមិត្តប្រុសច្រើនដងផងមុនពេលរៀបការនេះ ក៏គ្រប់យ៉ាងនឹងបញ្ចប់ត្រឹមពាក្យថា អតីតកាល។

អ្នកខ្លះស្តាយក្រោយ និងចង់បំបាត់ចោលអតីតកាលដែលពួកគេបានសាងឡើងខ្លួនឯង ប៉ុន្តែគ្មានអ្នកណាអាចកែវាទេ វាគ្រាន់តែជាអតីតកាល។ យើងមិនអាចត្រលប់ទៅផ្លាស់ប្តូរអតីតកាលបានទេ។

ចំណែកមនុស្សមួយចំនួនទៀតដូចខ្លួនខ្ញុំ ដែលមិនសូវមានពេលទៅលើការកសាងទំនាក់ទំនងច្រើនកាលពីអតីតកាល មិនចូលចិត្តដកពិសោធនិងដាក់កម្រិតរឿងស្នេហាពេក ក៏មានអ្នកស្តាយក្រោយព្រោះអស់ពេលវេលាដែរ។

ទោះយ៉ាងណាទាំងពីរយ៉ាងជាជម្រើសផ្ទាល់ខ្លួន ហើយមិនអាចកំណត់អត្តចរិត ឬភាពស្មោះត្រង់របស់បុគ្គលណាម្នាក់ ដោយផ្អែកលើរឿងអតីតកាលនោះបានឡើយ។

ជាពិសេសដូចជានៅពេលនេះ បុគ្គលដូចឡែនបែរជាមានការប្តេជ្ញាចិត្តក្នុងទំនាក់ទំនងយូរអង្វែងជាមួយមនុស្សចុងក្រោយ ខ្ញុំបែរជាយល់ថាបុរសនោះមិនអន់ទេ គាត់អស្ចារ្យណាស់ដែលធ្វើអោយមនុស្សដូចឡែនសំចតបាន។ ពួកគេនឹងមានជីវិតដ៏រីករាយមួយ។

តែអ្វីដែលខ្ញុំបារម្ភនិងគិតទុក បានកើតឡើងនៅថ្ងៃរៀបការនាង មិនមែនរឿងនាងទេ គឺរឿងខ្ញុំ ខ្ញុំបានឃើញVan ពីចម្ងាយ។ អ្វីមួយកន្ត្រាក់នៅក្នុងបេះដូងរបស់ខ្ញុំ។ ខ្ញុំមិនមែនជាមនុស្សជឿលើអតីតទេថែមទាំងគេនឹងខ្ញុំគ្មានអីនឹងគ្នាស្រាប់ហើយតែខ្ញុំមិនដឹងត្រូវធ្វើយ៉ាងណាសមរម្យសម្រាប់ដប់ពីរឆ្នាំដែលខ្ញុំមិនដែលសូម្បីតែបានឈែតជួបគ្នាជាមួយVan កុំថាឡើយជួបគ្នានិយាយក្រៅផ្ទាល់។

ខ្ញុំគេចមកក្នុងបន្ទប់កូនក្រមុំភ្លាម ស្រាប់តែឡែនទាញដៃខ្ញុំទៅជ្រុងស្ងាត់មួយ ខ្សឹបជាមួយខ្ញុំថា «ភ្ញាន់មិនទាន់រៀបការទេ! គេធ្វើការនៅកំពង់សោម! គេធ្វើការនៅក្រុមហ៊ុនដឹកជញ្ជូនធំមួយ ហើយតួនាទីក៏មិនតូចដែរ»

«ឯងប្រាប់យើងធ្វើស្អី?»

«យើងគ្រាន់តែចង់ប្រាប់នូវអ្វីដែលយើងទើបនឹងដឹងទៅឯង!»

«មិនបាច់ភ័យទេ ខ្ញុំនឹងរាក់ទាក់ជាមួយគេ! ប៉ុន្តែគ្មានអ្វីលើសពីនោះឡើយនាងឡែន!»

ខ្ញុំថាចប់ធ្វើឲ្យនាងញញឹមទាំងភ្នែកសម្លក់ខ្ញុំ។

ខ្ញុំដកដង្ហើមវែងៗតាំងចិត្តក្លាហានដើរចេញក្រៅរកគេ។ ខ្ញុំអាយុម្ភៃប្រាំបីឆ្នាំហើយគ្មានរឿងអ្វីខ្ញុំត្រូវខ្លាចនោះទេ ចំណែកដប់ពីរឆ្នាំមកនេះវាជារឿងឡប់បំផុតមួយបើមានអ្នកណាដែលគិតថា Van នៅតែមានចិត្តចំពោះខ្ញុំដូចកាលនៅវិទ្យាល័យ។

ខ្ញុំរកគេមិនឃើញទេ ខ្ញុំចង់ទៅនិយាយហេឡូជាមួយVanមុន ដូចដែលពួកយើងធ្លាប់ស្គាល់គ្នានិងរាប់អានគ្នាប៉ុន្តែគេបាត់ទៅណាក៏មិនដឹង។

ពេលដែលខ្ញុំដើររកចុះឡើងហើយរកមិនឃើញ ក៏ត្រឡប់មកចូលអង្គុយលើកៅអីវិញព្រោះហត់ ស្រាប់តែសំឡេងរបស់គេលាន់មកនៅក្បែរខ្ញុំចំពីក្រោយខ្នង៖

«វណ្ណារី»

គេហៅខ្ញុំខ្លី សូម្បីតែសួរថាសុខសប្បាយអត់ក៏អត់សួរ ប៉ុន្តែសំឡេងរបស់គេធ្វើឲ្យបេះដូងរបស់ខ្ញុំចង់គាំង។

ហេតុអីបានជាដប់ពីរឆ្នាំហើយ របៀបហៅរបស់Van មកកាន់ខ្ញុំមិនផ្លាស់ប្តូរសោះ?

ខ្ញុំបែរក្រោយទាំងញញឹម។

Van មានពាក់វ៉ែនតាមីញ៉ូប ប៉ុន្តែខ្ញុំនៅចំណាំបបូរមាត់របស់Van និងច្រមុះរបស់គេបានដែលគេនិយមញញឹមរកខ្ញុំរាល់ពេលហៅឈ្មោះខ្ញុំចប់។

ឃើញខ្ញុំរាប់រកហើយ គេប្រញាប់ទាញកៅអីមកអង្គុយក្បែរខ្ញុំតែម្តង។

«Van! ខានឃើញយូរហើយ»

«ខ្ញុំឃើញវណ្ណារីរាល់ថ្ងៃ!»

«អ្ហាក់? ឃើញនៅហ្នឹ!»

«ខ្ញុំមើលក្នុងហ្វេសប៊ុក»

អារម្មណ៍ចាស់បានវិលត្រឡប់មកវិញ ហេតុអីបានជាVan និយាយធ្វើមើលតែដប់ពីរឆ្នាំមិនបានរំលងទៅសោះ។ ទោះឥឡូវគេខ្ពស់ជាងមុន កាលពីមុនគេគឺកម្ពស់ប្រហាក់ប្រហែលខ្ញុំឥឡូវនេះជាVan ខ្ពស់ខ្លាំង ចំណែកខ្ញុំដូចជាមិនលូតខ្ពស់ជាងកាលពីនៅរៀនវិទ្យាល័យប៉ុន្មាននោះទេ ក្រិនតែម្តង។

«Van ធ្វើការនៅកំពង់សោមមែនអត់?»

«អ្នកណាប្រាប់?»

ខ្ញុំចង្អុលទៅក្នុងបន្ទប់កូនក្រមុំ ធ្វើឱ្យVanញញឹមមិននិយាយមិនស្តី។ ពួកយើងបានថតរូបច្រើនប៉ុស្តិ៍ជាមួយគ្នា ប៉ុន្តែគេមិនបានប្រាប់អំពីបណ្តាញសង្គមរបស់គេមកឲ្យខ្ញុំ ខាងខ្ញុំក៏មិនបានសួរនោះដែរ។

មកដល់ផ្ទះវិញ ខ្ញុំបានត្រឹមតែដឹងក្នុងចិត្តថា Van មានហ្វេសប៊ុករបស់ខ្ញុំ ដូច្នេះខ្ញុំមិនចង់ផុសពីអ្វីទាំងអស់ សូម្បីតែខ្ញុំដឹងថាគេបានថតរូបជាមួយខ្ញុំជាច្រើនសន្លឹកក៏ដោយ ក៏ខ្ញុំមិនចង់ឃើញមិនចង់ដឹង។ រឿងដែលខុសប្លែកមួយនៅល្ងាចនោះ ខ្ញុំចេះនឹកឃើញចង់ចេញទៅហាងទៅធ្វើសក់ឱ្យស្អាតទាន់សម័យ មិនព្រមនៅសំងំផាត់មុខធម្មតាខ្លួនឯងនៅផ្ទះដូចរាល់ដងទេ។

ទិន្នន័យនេះហាក់ចង់ប្រាប់ខ្ញុំថា ខ្ញុំចង់ឲ្យខ្លួនឯងមានសភាពស្រស់ស្អាតព្រោះមិត្តចាស់ជាច្រើននឹងមានវត្តមាន។ តែខ្ញុំមិនបានសំដៅលើVan ឡើយព្រោះខ្ញុំយល់ថា គេច្បាស់ជាមានសង្សារហើយ។ គេក៏សង្ហា មានឋានៈមួយ រាងខ្ពស់ សម្បុរសជាងកាលពីមុនឆ្ងាយ ហើយគេមានចំណេះដឹងជំនាញ មានសកម្មភាពល្អៗ ខ្ញុំក៏មិនដឹងថាគេរៀនខាងអី ប៉ុន្តែច្បាស់ណាស់ដប់ពីរឆ្នាំមកនេះ គេមានបទពិសោធការងារយ៉ាងច្រើន បើមើលទៅតាមសកម្មភាពរបស់គេ។ រឿងដែលមិនប្តូរនោះគឺគេនៅតែសម្លឹងមុខខ្ញុំរបៀបដដែល ដូចកាលនៅក្មេងៗ។

កាលគេហៅឈ្មោះខ្ញុំ ក៏របៀបដដែលទៀត។

«វណ្ណារី! បើយើងមិនឡើងរាំទេគ្មាននរណាចាប់ផ្តើមទេ!»

គេបានមកអញ្ជើញខ្ញុំឡើងរាំ។ ខ្ញុំញញឹមព្រោះខ្ញុំគ្មានអ្វីត្រូវខ្លាចហើយក៏មិនមានអ្វីត្រូវបដិសេធនោះដែរ។ មិននឹកស្មានថា បទនេះគឺជាចង្វាក់បែបនេះសោះ។

ដៃគេមកដាក់លើចង្កេះរបស់ខ្ញុំហើយគេចាប់ផ្តើមទាញដៃខ្ញុំទៅពាក់នៅពីលើស្មារបស់គេ។ យើងទាំងពីរនាក់រាំមុនអ្នកណាទាំងអស់ ជាមួយចង្វាក់ភ្លេងដ៏មនោសញ្ចេតនានេះ។

«ខ្មាសគេណាស់វណ្ណ! កុំធ្វើអ៊ីចឹង!»

ខ្ញុំមិនចង់ដាក់ដៃតាមរបៀបក្បាច់រាំនេះសោះ តែគេតបវិញមានហេតុផល។

«ដាឡែននិងប្តីគេរាំតែឯងហើយ បើយើងមិនបើកផ្លូវ!»

ទីបំផុតបានពីរគូមែនគឺកូនក្រមុំកូនកំលោះហើយគូយើង តែភ្លាមនោះគូទីបីបានបង្ហាញខ្លួនគឺរាជ និងភរិយាដ៏ស្រស់ស្អាតរបស់គេ។

ខ្ញុំសប្បាយចិត្តយ៉ាងខ្លាំង ព្រោះរាជរៀបការយូរហើយប៉ុន្តែពួកគេនៅតែផ្អែមល្ហែមដូចបទចម្រៀងយប់១២កើត។

«យប់នេះ ខ្ញុំមានក្តីសុខបំផុតបន្ទាប់ពីបែកវណ្ណារីជាង១០ឆ្នាំមក!»

នេះជាសម្តីដែលខ្ញុំទុកថាមិនបានឮទៅចុះប៉ុន្តែតាមពិត Van ពិតជាបាននិយាយមែន។ ខ្ញុំទម្លាក់ដៃចេញពីស្មារបស់គេហើយនិយាយឡើងភ្លាម៖

«ខ្ញុំគិតថាពេលវេលាកន្លងទៅយូរហើយ Vanមិនធ្វើអ៊ីចឹងទៀតទេ!»

«ធ្វើអី? ខ្ញុំបានធ្វើអីខុស? ខ្ញុំគ្រាន់តែស្រឡាញ់មនុស្សស្រីម្នាក់!»

«កុំនិយាយមើលទៅក្នុងកុនVan ! ពេលវេលាកន្លងទៅយូរហើយ គួរតែVan រកបានមនុស្សស្រីល្អ យើងរាប់អានគ្នាវាល្អពេកហើយ!»

«ខ្ញុំដឹងថាវណ្ណារីគ្មានសង្សារទេ!»

«ម៉េចក៏បានដឹង? ពូកែដឹងម៉េះ?» ខ្ញុំធ្វើហាក់ខឹងព្រោះគេគិតថាខ្ញុំនេះគ្មាននរណាស្រឡាញ់ឬក៏យ៉ាងម៉េច?

ខ្ញុំថាឱ្យVan ទៀត៖

«កុំធ្វើមើលតែខ្លួនឯងយុវវ័យអាយុ២០ និងធ្វើជាFBI តាមចេះដឹងគ្រប់រឿងរបស់ខ្ញុំ! ខ្ញុំមិនចូលចិត្តមានគេតាមដាន តាមសម្គាល់ទេ»

Van មិនខ្វីខឹងនឹងពាក្យព្រមានទាំងនេះ បែរជានិយាយខ្សាវឡើងៗ៖

«ខ្ញុំស្តាយណាស់រឿងពីមុន! ខ្ញុំនៅក្មេងខ្ចី មានចរិតកំសាក ខ្ញុំភ័យហើយឆាប់ខឹង ឆាប់បោះបង់ ប៉ុន្តែខ្ញុំឥឡូវមិនដូចមុនទេវណ្ណារី! ទោះបីជាវណ្ណារីថាឲ្យខ្ញុំបែបណាក៏ខ្ញុំនៅតែទៅរង់ចាំវណ្ណារីដដែល ហើយខ្ញុំមិន Give Up បោះបង់ចោលមនុស្សដែលខ្ញុំស្រឡាញ់ដោយងាយៗទៀតទេ!»

«Vanឯងស្រវឹងហើយ ញ៉ាំអស់ប៉ុន្មានកែវ?»

គេមិនឆ្លើយទេក៏សម្លឹងខ្ញុំដោយកែវភ្នែកស្រទន់។

«ខ្ញុំឈឺជើងVan ស្បែកជើងខ្ញុំខ្ពស់ពេក!»

ថាលេសនេះហើយខ្ញុំដកខ្លួនចេញពីការរាំ ដោយដើរមករកតុអាហារវិញ។ Van ក៏មកតាម។ យប់នោះគឺជាយប់ចុងក្រោយដែលខ្ញុំបានជួបគេ។

បើទោះបីជាខ្ញុំដឹងថាគេនៅក្បែរៗនេះ ឬក៏គេអះអាងថាគេតែងតែនៅកៀកខ្ញុំមើលឃើញខ្ញុំ តែខ្ញុំមិនដែលសួរពីអាខោនហ្វេសប៊ុករបស់គេឬមួយក៏សូម្បីតែលេខទូរសព្ទរបស់គេ ឬគេធ្វើការនៅកន្លែងណាខ្ញុំមិនខ្វល់នោះឡើយ។

ចាកចេញពីកម្មវិធីនោះមករំលងប្រហែលជាងមួយសប្តាហ៍ ខ្ញុំបានជួបបុរសម្នាក់។ គេជាអ្នកចំណូលថ្មីមកពីក្រៅប្រទេស។ គេត្រូវបានជួលមកធ្វើជាConsultancy បណ្តោះអាសន្ននៅក្នុងក្រុមហ៊ុនរបស់ខ្ញុំ។ គេមានឈ្មោះថា អេរិច ជាកូនខ្មែរប៉ុន្តែរស់នៅបរទេសច្រើនឆ្នាំ។

អេរិចនេះមានចរិតសុភាពរាបសា ហើយស្អាតសង្ហារហូតដល់គ្រប់មនុស្សស្រីចាប់អារម្មណ៍លើគេតាំងពីថ្ងៃជួបគ្នាដំបូងបាន។ មនុស្សដូចគេ ដែលមានឋានៈខ្ពស់គួរសមនៅក្នុងចំណោមអ្នកធ្វើការរបស់យើង និងមានកាយសម្បទាល្អទៀត បានជាស្រីក្មេងៗជាច្រើនប្រជែងគ្នាបង្ហាញសម្រស់ដូចជាផ្ការីកស្គុសស្គាយនៅក្នុងក្រុមហ៊ុននៅពេលមានវត្តមានរបស់គេ។

រឿងសំខាន់គឺអេរិចបង្ហាញនូវសញ្ញាវិជ្ជមានថាចាប់អារម្មណ៍ចំពោះខ្ញុំទៅវិញ។

ចុងក្រោយត្រូវមកធ្វើការនៅក្នុងបន្ទប់ជាមួយខ្ញុំដោយសារការងារដែលត្រូវផ្តល់យោបល់ភាគច្រើនផ្អែកទៅលើផ្នែករបស់ខ្ញុំ ជាឱកាសដែលធ្វើឲ្យនារីភាគច្រើនច្រើន នៅទីនេះបានលបលួចច្រណែនខ្ញុំ។

មនុស្សជាច្រើនមើលមកថា ពួកយើងដូចជាស្រមោចនិងស្ករ។ ខ្ញុំជាស្រីក្រមុំហើយគាត់គឺជាកម្លោះដែលមានចិត្តទូលាយដែរ ថែមទាំងឮមកថាកំពុងចង់បានស្នេហានៅភ្នំពេញផងដូច្នេះហើយមន្តស្នេហ៍ដែកឆក់របស់ខ្ញុំនៅតែមានប្រសិទ្ធិភាពឡើង សូម្បីតែជាមួយកំលោះមកពីស្រុកក្រៅម្នាក់នេះ។

រួចអេរិចក៏បានទិញផ្កាបាច់មកជូនខ្ញុំដោយបើកចំហជាកិច្ចសារភាពស្នេហ៍ ស្ទីលក៏ដូចជាធ្វើឲ្យគ្រប់គ្នាដឹងថា ពួកគេគួរតែបញ្ឈប់នូវក្តីសុបិននៅក្នុងការចូលទៅក្នុងបេះដូងរបស់អេរិចទៀតពីព្រោះបេះដូងគេបាន ទទួលយកខ្ញុំចូលទៅពេញប្រៀបទៅហើយ។

សេចក្តីស្នេហាមួយនេះ ជារឿងដែលភាគីទាំងសងខាងមានចំពោះគ្នា។ ទាំងខ្ញុំ ទាំងគេ សុទ្ធតែទន្ទឹងរង់ចាំឱ្យវាកើតមានឡើង ដូច្នេះហើយវាគ្មានអ្វីដែលថាមិនរលូននោះទេ។

ទីបំផុតទៅការណាត់ជួបដំបូងរបស់ពួកយើងបានធ្វើឡើងយ៉ាងតក់ក្រហល់ទាន់ហន់ តាមរបៀបព្រមព្រៀងដូចស្ទីលយុវវ័យទាន់សម័យទាំងអស់ដែរ។

ខ្ញុំនិងគេបានជួបគ្នាជាមួយនឹងការតុបតែងខ្លួនយ៉ាងរំភើបរំជើបរំជួល។ ចំណែកអ្វីៗក៏បានលោតផ្លោះលើសពីការរំពឹងទុកក្នុងយប់នោះ ដោយខ្ញុំអត់បានត្រឡប់មកផ្ទះវិញទេ។

ស្នេហាពួកយើងបានឈានដល់ទីជម្រៅនេះដោយសារតែខ្ញុំជាមនុស្សមានការតាំងចិត្តច្បាស់លាស់មុតមាំចំពោះស្នេហា។ ខ្ញុំមិនងាយមានអ្នកណា តែបើមាន ខ្ញុំមិនលែងសើចឡើយ។

ជាមួយអេរិច ដូចដែលគេបានបង្ហាញនូវអ្វីៗដោយចំហ បញ្ជាក់ថាខ្ញុំនេះគឺជាមនុស្សសំខាន់របស់គេ ម្ល៉ោះហើយអាពាហ៍ពិពាហ៍រវាងពួកយើង រមែងស្ថិតនៅក្នុងសុបិនរបស់ខ្ញុំជារៀងរាល់ថ្ងៃ ដោយចាប់ផ្ដើមគិតតាំងពីរឿងមានកូនផ្ទះតូចមួយ រស់នៅដាច់ដោយឡែកជាមួយអេរិចហើយនិងការឈរជើងរបស់គេនៅភ្នំពេញ ពួកយើងនឹងអាចរស់នៅក្នុងជីវភាពល្អប្រសើរបើតាមសមត្ថភាពនិងបទពិសោធអាជីពសងខាង។

ករណីរបស់ពួកយើងមិនខុសពីលំនាំឡែន ហើយនិងប្ដីសាស្ត្រាចារ្យរបស់នាង ឬក៏រាជនិងកូនអ្នករកស៊ីធំនៅខេត្តនោះទេ។

គ្រប់គ្នាបានមកដល់កន្លែងសប្បាយចិត្តមួយ។ ហេតុអីគិតដល់ចំណុចនេះខ្ញុំនឹកឃើញVan ភ្លាម?

ខ្ញុំនឹកឃើញថា ហេតុអ្វីបានជានៅក្នុងចំណោមគ្នាយើងនៅសល់ Vanមួយ មិនព្រមស្វែងរកសុភមង្គលឲ្យខ្លួនឯង ដូចជាពួកយើង?

ខ្ញុំចង់បានលេខទំនាក់ទំនងរបស់គេ! ខ្ញុំចង់បានពេលវេលាមួយនិយាយប្រាប់គេឲ្យយល់និងគិតឡើងវិញច្បាស់លាស់អំពីស្នេហានិងឆាកជីវិតរបស់មនុស្ស កុំឲ្យគេបន្តមានះរឹងទទឹងជាមួយរឿងអតីតកាលព្រោះថាតាំងពីដើមមក ខ្ញុំមិនដែលមានគំនិតអ្វីលើគេនោះទេ។

ខ្ញុំក៏ដាច់ចិត្តសុំលេខគេពីរាជ។ រាជបានឲ្យលេខទូរសព្ទVan មកខ្ញុំ។

ខ្ញុំក៏បានឆែតទៅគេមុនថា៖

«រាត្រីសួស្ដីអីVan!»

«ខ្ញុំដឹងរឿងដែលវណ្ណារីចង់និយាយហើយ!»

«ពូកែដឹងម៉េះ? ស្គាល់លេខខ្ញុំទៀត?!»

«ខ្ញុំស្គាល់លេខវណ្ណារីច្បាស់ជាងគេក្នុងចំណោមអ្នកទាំងអស់ដែលស្គាល់គ្នា»

នេះនៅតែឆ្លើយមកឌឺដង។

«ខ្ញុំជិតរៀបការហើយ Van! ខ្ញុំមានបំណងជួបនិយាយលេងជាមួយVan អំពីបញ្ហាជីវិត!»

«ខ្ញុំដឹងតាស!»

«Van ឯងធ្វើជាប៉ូលិសស៊ើបអង្កេត ឬធ្វើការអីនៅកំពង់សោម?!»

«ទាំងពីរយ៉ាង!»

ខ្ញុំសើចៈ

«ឈប់និយាយលេងសើចទៅ យើងចាស់ៗហើយ!»

«ព្រោះតែយើងចាស់ៗហើយ បានជាខ្ញុំមិននិយាយលេងសើចទេ! អាពាហ៍ពិពាហ៍នេះវណ្ណារីឯងគួរតែគិតឡើងវិញ ខ្ញុំទេដែលជាអ្នកស្រឡាញ់វណ្ណារីខ្លាំងមិនមែនម្នាក់ហ្នឹងទេ!»

ខ្ញុំលែងបកស្រាយ តែបានណាត់ជួបគេដើម្បីញ៉ាំកាហ្វេជាមួយគ្នានៅថ្ងៃស្អែកឡើង។ នៅពេលញ៉ាំកាហ្វេនោះខ្ញុំបាននិយាយប្រាប់គេថាមានរឿងជាច្រើនណាស់បញ្ជាក់ច្បាស់ ថាខ្ញុំពិតជាស្រឡាញ់អេរិច ហើយថាស្នេហារបស់ពួកយើងបានឈានដល់ការព្រមព្រៀងប្រើជីវិតជាមួយគ្នាដែរ។

Van ក៏ទទួលយល់ព្រមយកកំណាចព្រហ្មលិខិតមួយនេះ។ គេជូនពរខ្ញុំ ថែមទាំងមិនបាននិយាយអ្វីធ្វើឲ្យខ្ញុំពិបាកចិត្តនោះទេ។

យើងសន្យាថានឹងនៅតែរាប់អានគ្នា ហើយគេក៏សន្យាថានឹងឲ្យដំណឹងមកខ្ញុំមុនគេឯង ប្រសិនគេរកបាននារីណាម្នាក់ដែលគេសម្រេចចិត្តរៀបការជាមួយ។

ល្ងាចនោះពេលត្រឡប់មកផ្ទះវិញខ្ញុំឃើញអេរិចហាក់មិនសប្បាយចិត្តជាខ្លាំង។

ពេលខ្ញុំសួរនាំគេ ទីបំផុតខ្ញុំដឹងថាគេមានបំណងចង់ត្រឡប់ទៅកាន់ប្រទេសអូស្ត្រាលីវិញ ដោយហេតុផលថានៅទីនោះមានឱកាសការងារច្រើនជាងនិងចំណូលខ្ពស់ជាង។

ដែលគេមិនសប្បាយចិត្តគឺ មិនដឹងធ្វើម៉េចខ្ញុំបានទៅជាមួយគេ។ ខ្ញុំក៏ប្រាប់គេវិញថា ខ្ញុំមិនទាន់គិតអំពីរឿងទៅនៅបរទេសនៅឡើយ ពីព្រោះខ្ញុំមានការងារល្អនៅភ្នំពេញហើយខ្ញុំកំពុងតែជក់ចិត្តនៅក្នុងការកសាងឋានៈតាមជំនាញខ្ញុំដែលបានកសាងមកយូរហើយ។

មួយវិញទៀតខ្ញុំបានប្រញាប់ប្រាប់ដំណឹងរីករាយមួយដល់គេថា ខ្ញុំមានផ្ទៃពោះហើយ។ ក៏ស្រាប់តែដំណឹងនេះ មិនបានធ្វើឲ្យគេផ្លាស់ប្ដូរមករំភើបរីករាយអ្វីដូចដែលខ្ញុំបានរំពឹងទុកសោះ។

សភាពរបស់គេ ខ្ញុំឃើញហើយយល់ថាគេមិនបានប្ដេជ្ញាចិត្តចំពោះស្នេហាពួកយើងទេ។

«យើងមិនសមនឹងមានកូនក្នុងពេលនេះទេ!»

ខ្ញុំដាច់ផ្កាដូចជាត្រូវរន្ទះបាញ់ ឬអាចនិយាយបានថាកំពុងឈរកណ្ដាលថ្នល់ហើយត្រូវកិនសំប៉ែតទាំងគ្មានកម្លាំងរើនឹងការវាយប្រហារនេះ។

ហេតុអីមនុស្សប្រុសម្នាក់ដែលយើងគិតថានឹងរួមរស់ជាមួយ បែរជាមកនិយាយពាក្យបែបនេះតើក្នុងពេលដែលយើងកំពុងស្ថិតក្នុងបំលាស់ប្ដូរដ៏ស្មុគស្មាញមួយ?

វាមានន័យដូចម្ដេចគ្រាន់តែពាក្យមួយម៉ាត់ថា មិនទាន់ដល់ពេលដែលត្រូវមានកូន?

ប៉ុន្ដែរឿងសម្លាប់ជីវិតទារកដែលកំពុងតែលោតចង្វាក់បេះដូងតូចច្រម៉ក់នៅក្នុងផ្ទៃរបស់ខ្ញុំពិតជារឿងមួយដែលខ្ញុំមិនដែលត្រៀមទុកមុននោះទេ ហើយខ្ញុំក៏មិនគិតថាខ្ញុំនឹងអាចឲ្យមនុស្សប្រុសដែលសម្លាប់កូនរបស់ខ្ញុំ យកដៃរបស់គេមកប៉ះលើខ្លួនប្រាណខ្ញុំទៀតនោះដែរ។

មិនថាហេតុផលអ្វីក៏ដោយ ខ្ញុំដើរចេញហើយគេងយំជាខ្លាំងពេញមួយយប់នោះ។

ស្អែកឡើងគេនៅតែឃែតមកប្រាប់ខ្ញុំថា គេបានសម្រេចចិត្តច្បាស់ពីរឿងវិលត្រឡប់ទៅរស់អូស្ត្រាលីវិញ ដោយសារប្រាក់ខែនៅទីនោះមានតម្លៃប្រាំដងនៃអ្វីដែលគេរកបាននៅភ្នំពេញ។ ការដែលគេមកភ្នំពេញរយៈពេលប៉ុន្មានខែនេះ គ្រាន់តែដើម្បីធ្វើការងារមួយចំនួនសន្សំក្រេឌីតនៅប្រទេសក្រីក្រ ដូចជាបានបរិច្ចាគជួយចំពោះពិភពលោកទៅចុះ ចំណែកគោលដៅពិតប្រាកដរបស់គេ មិនមែនសាងអ្វីៗនៅភ្នំពេញដូចនិយាយកាលពីតាមស្រឡាញ់ខ្ញុំពីដំបូងនោះឡើយ។

ហេតុអីបានជាពេលដែលគេសុំស្រឡាញ់ខ្ញុំ គេមិនដែលនិយាយរឿងទាំងអស់នេះឡើងមក? ហេតុអីបានជាយើងមិនដែលគិតដល់រឿងជាច្រើនទៀត អាចកើតមានឡើងនៅក្រោយការស្រឡាញ់គ្នា?

ខ្ញុំក៏គិតដល់សម្តីរបស់Vanដែលបាននិយាយកាលឱបខ្ញុំរាំនោះថា «ខ្ញុំស្តាយដែលខ្ញុំធ្លាប់Give Up ចំពោះវណ្ណារីឯង! កាលនោះខ្ញុំនៅក្មេងពេក តែឥលូវខ្ញុំមិនធ្វើអ៊ីចឹងទៀតទេ!»

មនុស្សប្រុសដូចគ្នាមែន! គេតែងតែចាត់ទុកស្នេហាថាជាជើងបន្ទាប់ ឬជាជម្រើសអត់សំខាន់ក្រោយពេលបានអ្វីៗគ្រប់យ៉ាងហើយ។

បែបនេះហើយក្តី ខ្ញុំមិនអស់ចិត្តនៅឡើយ។ ខ្ញុំមិនចង់ក្លាយជាមនុស្ស Give Up ឆាប់ពេកចំពោះឧបសគ្គស្នេហ៍នោះទេ។ ខ្ញុំក៏សម្រេចចិត្តថា ទៅជួបគេនិយាយជាមួយគេឲ្យច្បាស់។ ពេលដែលខ្ញុំទៅដល់ អ្វីដែលខ្ញុំឃើញលើសពីអ្វីដែលខ្ញុំគួរតែដឹង។

ខ្ញុំមិនគួរមកល្អជាង!

តាមពិតអេរិចមានទំនាក់ទំនងជាមួយកូនស្រីច្បងនៃCEOក្រុមហ៊ុនដែលខ្ញុំកំពុងធ្វើការ។ ពួកគេទាក់ទងគ្នាពីពេលណាខ្ញុំមិនដឹងទេ។ ខ្ញុំមិនដឹងថាខ្ញុំជាអ្នកមកដល់ក្រោយឬមកដល់មុនឡើយ ដឹងត្រឹមថាពួកគេត្រូវរ៉ូវគ្នាក្នុងការចាកចេញពីខ្ញុំ។ មនុស្សស្រីនោះឯងដែលនឹងចេញទៅបរទេសជាមួយគេ។

អេរិចនៅពេលនេះគេបានមនុស្សដែលគេស្រឡាញ់ទៅជាមួយហើយ ថែមទាំងបានធ្វើការនៅប្រទេសដែលគេចង់ធ្វើ ឬមួយក៏ទាំងនេះគឺជាលេសដើម្បីចាកចេញពីខ្ញុំតែប៉ុណ្ណោះ?

ព្រោះគេមានខ្ញុំគ្រាន់តែជាការបើកឆាកនៃសេចក្តីស្នេហាមួយដែលចិត្តគេចង់សាកល្បង ក្រោយមកក៏ដឹងច្បាស់ថាគេមិនចង់បានស្នេហាមួយនេះ ថែមទាំងមិនចង់បានម្តាយកូនយើងទៅឆ្លងកាត់ជីវិតនៅសល់ជាមួយគេ?

យប់នោះខ្ញុំយំទៀត យំព្រោះមិននឹកស្មានថាមនុស្សដូចខ្ញុំ ទីបំផុតមានលទ្ធផលបែបនេះ។

ចំពោះរឿងជាមួយអេរិច ខ្ញុំដឹងថាត្រូវធ្វើម៉េចហើយ ការបែកពីមនុស្សស្មោះទើបលំបាកតែបែកពីព្រានកំណាចមិនលំបាកធ្វើចិត្តទេ ប៉ុន្តែតើខ្ញុំនឹងធ្វើម៉េចតទៅទៀតចំពោះកូននៅក្នុងពោះ?

អ្នកដែលខ្ញុំត្រូវនិយាយជាមួយគ្មាននរណានោះទេច្បាស់ហើយគឺម៉ាក់របស់ខ្ញុំ។ ម្តាយរបស់ខ្ញុំនិយាយថា យើងគួរប្តូរទីលំនៅហើយគាត់នឹងចិញ្ចឹមចៅនេះ។ គាត់ប្រាប់ថា ឲ្យខ្ញុំឈប់ធ្វើការមួយរយៈប្រើលុយដែលយើងសន្សំបានថែទាំខ្លួនឲ្យក្មេងកើតមកសិនចាំរកការងារធ្វើទៀត។ នេះគឺជាជម្រើសតែមួយ ខ្ញុំគ្មានផ្លូវផ្សេងនោះទេ។

យ៉ាងហោចណាស់នេះគឺជាបំណុលជីវិតមួយដែលខ្ញុំបានសាងឡើង ហើយខ្ញុំជាអ្នកសង មិនមែនឲ្យកូនខ្ញុំសងនោះឡើយ។

ខ្ញុំបានធ្វើដូចគម្រោងទុក គឺចាកចេញពីក្រុមហ៊ុននេះរយៈពេលមួយខែក្រោយមក។

ខ្ញុំបានមកនៅខេត្តឆ្ងាយមួយ មិនមែនកំពតដែលមានរាជ មិនមែនភ្នំពេញដែលមានឡៃនហើយក៏មិនមែនកំពង់សោមដែលមានVan ដែរ។

ខ្ញុំសម្រេចចិត្តមករស់នៅកន្លែងដែលគ្មានអ្នកណាស្គាល់ ហើយចាប់ផ្ដើមត្រៀមលក្ខណៈគ្រប់គ្រាន់នៅក្នុងការប្រសូតកូនកម្សត់ម្នាក់នេះចេញមក។

គ្រប់យ៉ាងនឹងរៀបចំគម្រោងបន្តនៅក្រោយពិធីឃើញពន្លឺថ្ងៃរបស់គេ។

ពេលនេះដល់ខែទីប្រាំបីហើយ។ ពោះខ្ញុំខ្វាតធំមែនទែន ខ្ញុំសឹងអង្គុយរៀនអនឡាញមិនបាន។ ខ្ញុំតាំងចិត្តយកពេលនេះរៀនជំនាញបន្ថែមខ្លះទៀត បន្ថែមយកសញ្ញាបត្រនិងជំនាញរកការងារធ្វើក្រោយកូនកើតមក។

អ្នកនៅជុំវិញទីនេះគ្មាននរណាមានឱកាសក្នុងសួរថា ប្ដីខ្ញុំជាអ្នកណានោះទេពីព្រោះខ្ញុំក្រចេញពីផ្ទះបំផុត។

ខ្ញុំរស់នៅតែជាមួយម្ដាយខ្ញុំ ដែលយូរៗម្ដងមានបងប្អូនខាងម្ដាយខ្ញុំពីរបីនាក់មកស្នាក់នៅ គេងលេងជាមួយយើង។

ម្ដាយខ្ញុំក៏បានធ្វើមុខរបរតូចតាចមួយ គឺការលក់អង្ករទិញដុំមកលក់រាយនៅនឹងមុខផ្ទះ ចំណែកខ្ញុំនៅសំងំតែនៅជាន់ខាងលើដើម្បីធ្វើការសិក្សាអនឡាញ។

ស្រាប់តែ....

«វណ្ណារីមានគេមករកកូន!»

ខ្ញុំលបសម្លឹងពីបង្អួចខាងលើទៅក្រោម។ អ្នកណាទៅ មករកនិងស្គាល់ខ្ញុំផង? តាមរកអីដល់កន្លែងលាក់ប្រវត្តិនេះ?

ទោះបីមើលពីក្រោយនិងផិតផើយបិទបាំងជាមួយស្លឹករុក្ខជាតិ ខ្ញុំដឹងថានោះគឺVan។ ខ្ញុំត្រេកអរខ្លាំង ព្រោះអារម្មណ៍មនុស្សស្រីមានផ្ទៃពោះដែលគ្មានញាតិផៅ គឺឯកោខាងអារម្មណ៍។

ចំពោះVan ឡែន និងរាជ គឺជាមនុស្សជិតស្និទ្ធបន្ទាប់ពីម្តាយរបស់ខ្ញុំ ប៉ុន្តែអារម្មណ៍មួយទៀតបានកើតក្នុងពេលដំណាលគ្នាគឺសភាពរបស់ខ្ញុំពេលនេះ ខ្ញុំបង្ហាញVan ជួបVan បានដែរទេ?

ទោះបីយ៉ាងណា ខ្ញុំពិតជាបានចុះទៅជួបគេ។

ខ្ញុំអាយុម្ភៃប្រាំបួនឆ្នាំហើយ ខ្ញុំគ្មានអីត្រូវខ្លាច គ្មានអីត្រូវគេចវេះទាំងអស់។

«Vanមានការអីបានមកដល់ខេត្តនេះ?»

«ខ្ញុំទៅធ្វើការនៅស្រុកថៃ ហើយត្រូវធ្វើដំណើរតាមព្រំដែនគោក ក្រុមហ៊ុនខ្ញុំឱ្យយកអំណោយមកចែកខ្លះសម្រាប់ប្រជាជនដែលលិចទឹកនៅកន្លែងនេះ ខ្ញុំដឹងថាវណ្ណារីរស់នៅហ្នឹងខ្ញុំក៏ឆៀងមកលេង»

«ពូកែដឹងណាស់Van នៅហ្នឹង ខ្ញុំអត់ទាន់បានប្រាប់អ្នកណាសោះហ្នឹង!»

ខ្ញុំនិយាយតិចៗប៉ុន្តែក្នុងបេះដូងខ្ញុំឈឺផ្សាដោត។ សម្តីរបស់គេទាំងប៉ុន្មានលាន់ឡើងមកវិញក្នុងការចងចាំរបស់ខ្ញុំ «ខ្ញុំដឹងរឿងវណ្ណារីទាំងអស់ លើកនេះខ្ញុំមិនGive UP ទេ» ខ្ញុំស្មានតែគេនិយាយលេង។

«បើបានមកហើយ Van នៅសម្រាកហ្នឹងសិនទៅ ខ្ញុំរៀបចំធ្វើមាន់!»

«ប្រាកដហើយខ្ញុំមកលេងវណ្ណារីច្បាស់ជាចង់ញ៉ាំបាយជាមួយគ្នាតែខ្ញុំ ក៏យកម្ហូបមកតិចតួចដែរ! ចាំខ្ញុំជាអ្នកធ្វើ!»

«ល្អហើយអ៊ីចឹង ខ្ញុំសប្បាយចិត្តពីព្រោះថាខ្ញុំកំពុងហត់នឿយ និងកំពុងឯកោគ្មាននរណាម្នាក់ញ៉ាំបាយជាមួយគ្នា»

«ល្អណាស់ យើងញ៉ាំបាយជាមួយគ្នា!»

ថាហើយគេទៅចាត់ចែងធ្វើ។

យើងហូបបាយតែពីរនាក់ព្រោះម្តាយខ្ញុំគាត់រវល់លក់នៅខាងមុខ ម្យ៉ាងទំនងជាគាត់ចង់ឲ្យពួកយើងបានជជែកគ្នាផង។

«កូនប្រុសឬក៏ស្រី?» គេសួរខ្ញុំ ខ្ញុំប្រាប់ថាគឺជាកូនប្រុស។

Vanមិនមានបង្ហាញទឹកមុខអ្វីដែលធ្វើឱ្យខ្ញុំត្រូវទៅបែងចែកអារម្មណ៍គិតទើសទាល់នោះទេ។ ក្រៅពីទុកចិត្ត មានសុវត្ថិភាពនិងស្និទ្ធស្នាលជាមួយគ្នានោះហើយ គេក៏មិនបានសួរសូម្បីតែមួយម៉ាត់ណាពីអេរិច។

ពេលគេកំពុងលាងចាន ខ្ញុំទៅឈរក្បែរជួយជូត ស្រាប់តែគេនិយាយឡើងថា៖

«ពេលខ្ញុំមកពីថៃវិញ ខ្ញុំឡើងមកជូនវណ្ណារីឯងទៅដើរលេងនៅកំពង់សោមស្រឡះមុខមាត់ម្តង! ខ្ញុំមានផ្ទះមួយតូច យើងអាចស្នាក់នៅទីនោះទាំងអស់គ្នាបាន!»

មិនដឹងថាជាចេតនាអីទេគេមកបង្ហាញខ្លួនពេលនេះ។ ឥឡូវគេមកស្នើបែបនេះទៀត។ ខ្ញុំងើបមុខសម្លឹងVanទាំងក្រៀមក្រំ។ ចិត្តខ្ញុំគ្មានទេសេចក្តីស្នេហាស្រើបស្រាល ត្រេកត្រអាលអ្វី ខ្ញុំក៏គ្មានប៉ងអ្វីនៅក្នុងការនិយាយទាក់ទាញចិត្តVan ឬមួយក៏សើុបសួរពីទឹកចិត្តរបស់គេចំពោះខ្ញុំនោះដែរ ស្នេហានៅតែសាបឈឹងទៅហើយក្នុងអារម្មណ៍របស់ខ្ញុំ។ រវាងមនុស្សប្រុសនិងមនុស្សស្រីខ្ញុំគ្មានពេលគិតទេ ពីព្រោះខ្ញុំបានផ្តល់ការស្រឡាញ់និងក្តីសង្ឃឹមទាំងអស់ទៅឲ្យទារកដែលកំពុងតែកម្រើកចុះឡើងក្នុងផ្ទៃរបស់ខ្ញុំ។

កិរិយានីមួយៗរបស់Van ឆ្លៀតឱកាសនាំមកនូវសម្ពាធនៃការពិចារណាសម្រាប់ខ្ញុំឡើងៗ។ សម្តីប្រាកដប្រជារបស់គេមួយៗប៉ះពាល់ដល់ចិត្តខ្ញុំជាខ្លាំង មិនមែនមានន័យថាគេជាមនុស្សអាក្រក់ធ្វើឲ្យខ្ញុំមានបញ្ហាផ្លូវចិត្តទេ ប៉ុន្តែសេចក្តីស្នើរបស់គេពិតជាធ្វើខ្ញុំមានអារម្មណថាខ្លួនឯងកំពុងសាងនិងបានសងរួចមកហើយនូវអ្វីមួយខុសៗចំពោះខ្លួនឯងនិងចំពោះVan។

«ខ្ញុំមានពោះពុង ខ្ញុំមិនចង់ទៅឆ្ងាយទេVan!»

ខ្ញុំនិយាយដោយស្រពោន តែតាមពិតមកពីខ្ញុំមិនចង់ជួបជាមួយរាជឬអ្នកណាក្នុងសភាពរបៀបនេះសភាពជាមនុស្សស្រីពោះធំដែលគ្មានប្តី។

ស្រាប់តែVanថាមកទៀតក្នុងសព្ទសំឡេងមួយៗច្បាស់ៗ៖

«ខ្ញុំមានការងារជាង១០ថ្ងៃនៅស្រុកថៃ! ការងារនេះរាងធ្ងន់បន្តិចពិបាកបន្តិចដែលខ្ញុំត្រូវដោះស្រាយវាដោយខ្លួនឯងឲ្យចប់សព្វគ្រប់! ពេលត្រឡប់មកវិញខ្ញុំរៀបការជាមួយវណ្ណារីបើសិនជាវណ្ណារីយល់ព្រម ហើយកូនរបស់វណ្ណារីគឺជាកូនរបស់ខ្ញុំ ខ្ញុំនឹងចិញ្ចឹមបីបាច់គេឱ្យក្លាយជាក្មេងល្អម្នាក់!»

មិនហ៊ានងើបមុខសម្លឹងVan នោះទេ ហើយខ្ញុំក៏មិនទន់ជ្រាយឱ្យគេមកអាណិតដែរ ព្រោះខ្ញុំនឹងមិនទទួលយកចិត្តសប្បុរសនេះស្រាប់ហើយ។ ខ្ញុំដឹងច្បាស់ចិត្តខ្លួនឯង។ ខ្ញុំមិនកេងចំណេញទៅលើមនោសញ្ចេតនារបស់Vanហើយខ្ញុំ ក៏មិនមែនជាមនុស្សផុនឆ្លៀតឱកាស ថែមទាំងខ្ញុំមិនត្រូវការអ្នកណាមកស្រោចស្រង់ខ្ញុំនោះដែរ។ ខ្ញុំមានសុភមង្គលក្នុងការរស់នៅជាខ្លួនឯង ពីភាពងងឹតរើខ្លួនមករកពន្លឺ ហើយខ្ញុំអាចធ្វើវាបាន ប៉ុន្តែមិនដឹងហេតុអីបានជាទឹកភ្នែកខ្ញុំស្រក់ចុះមកទប់មិនជាប់សោះ?

គេឈប់លាងចានហើយបែរមកបញ្ជាក់៖

«ខ្ញុំត្រូវទៅទៀតហើយ! តែគ្រប់យ៉ាងដែលខ្ញុំបាននិយាយសុទ្ធតែជាការពិត!»

«ខ្ញុំមិនមើលទៅគួរឱ្យអណោចអាធម៌ដល់Van ត្រូវប្រើជីវិតខ្លួនឯងមកជួយទេដឹង?!»

«ឆ្កួត! គឺវណ្ណារីទេដែលជួយខ្ញុំឱ្យចេញពីភាពអស់សង្ឃឹម!»

ថាហើយគេដើរចាកចេញទៅតម្រង់ទ្បាន តែខ្ញុំដើរតាមទៅដែរទាំងស្រែកសួរព្រមទាំងយំផង៖

«ស្អីទៅ Vanឯងហ្នឹងអស់សង្ឃឹម?»

«ខ្ញុំអស់សង្ឃឹមថាជាតិនេះរកបានគ្រួសារមួយល្អនឹងគេ! បើវណ្ណារីឯងឱ្យមកខ្ញុំ ខ្ញុំនឹងចាប់ឱ្យជាប់ឱកាសមួយនេះ!»

ខ្ញុំឈរផ្អឹងពេលVanចេញទៅ។ ម៉ែបានមកប្រាប់ថា Van បានទុកនូវសម្ភារៈទារកជាច្រើន។ គាត់សួរខ្ញុំថាតើVan ធ្លាប់មានប្រពន្ធដែរទេ ហេតុអីបានជាចេះយកចិត្តទុកដាក់ និងល្អិតល្អន់ដូចជាមនុស្សដែលធ្លាប់មានគ្រួសារ?

ខ្ញុំតបប្រាប់ម្តាយខ្ញុំវិញថា Van មានចរិតពីក្មេងមកជាមនុស្សដូច្នេះ។ គេនេះរញ៉ាំរញ៉ូវ ល្អិតល្អោចតាំងពីនៅរៀន ចូលចិត្តសង្កេត តាមដានយើង ចេះប្រចណ្ឌហើយនិងច្រណែនសូម្បីតែប្រុសៗកូនចិននៅម្តុំផ្ទះយើងដែលតាមលបមើលខ្ញុំដើរទៅរៀន។

ម្តាយខ្ញុំជជីកសួរទៀតថា ចុះគេនេះមានប្រពន្ធឬនៅកូន ហេតុអីបានជាកូនមិនពិចារណាគេ?

«ម៉ាក់កុំនិយាយរឿងនេះទៀត! រឿងហួសឆ្ងាយយូរហើយ ជាងដប់ឆ្នាំហើយម៉ាក់!!»

«ក្មេងប្រុសម្នាក់នោះស្រឡាញ់កូនស្រីរបស់ម៉ាក់ច្បាស់ណាស់»

ម្តាយខ្ញុំនិយាយ។

យប់នោះខ្ញុំគេងមិនលក់ពេញមួយយប់ព្រោះរឿងVan បង្ហាញខ្លួន។

ខ្ញុំអង្គុយមុខផ្ទះសម្លឹងព្រះចន្ទនៅលើមេឃ ហើយចេះតែចង់សួរទៅកាន់ភពផែនដីនេះថា តើនេះឬមនុស្សដែលខ្ញុំ នៅតែជួបវិលចុះវិលឡើងក្បែរៗជីវិតរបស់ខ្ញុំ?

ព្រោះថាខ្ញុំជំពាក់អ្វីម៉្យាងឬមួយក៏គេពិតជាមនុស្សសម្រាប់ខ្ញុំ?

ដោយសារតែសមត្ថភាព ភាពរឹងទទឹង និងចរិតមោទនភាពចំពោះខ្លួនឯងរបស់ខ្ញុំ បានជាខ្ញុំបានរំលងទៅនូវមនុស្សល្អនេះ  ម្តងហើយម្តងទៀតរហូតដល់ព្រហ្មលិខិតទម្លាក់មកឲ្យខ្ញុំនូវចំណោទធំមួយនៅពេលនេះ ទើបខ្ញុំត្រូវការដឹងនិងមកវិភាគអំពីទឹកចិត្តគេ?

ហេតុអ្វីបានជាគេនៅតែចង់រៀបការជាមួយមនុស្សស្រីម្នាក់ ដែលមិនមែនដូចពីមុន?

រំលងបានមួយសប្តាហ៍ខ្ញុំស្រាប់តែឈឺពោះខ្លាំង។ ពេលមកដល់សម្ភព ខ្ញុំបានសម្រាលកូនប្រុសមួយទ្រលុកទ្រលន់ក្រោមការមើលថែរបស់ម្តាយខ្ញុំ។

ប៉ុន្តែរឿងដែលខ្ញុំឆ្ងល់នោះ    គឺស្អែកឡើងស្រាប់តែខ្ញុំឃើញមានបុរសចំណាស់និងស្ត្រីចំណាស់ម្នាក់ ទៀតរូបរាងស្លៀកពាក់តែងតួជាអ្នកភ្នំពេញ បានមកដល់មន្ទីរពេទ្យនេះរួច ពួកគេពរកូនប្រុសរបស់ខ្ញុំផង។

នៅពេលដែលខ្ញុំភ្ញាក់ដឹងខ្លួនឡើង   ខ្ញុំសួរម្តាយខ្ញុំរឿងនេះ   ថាហេតុអ្វីបានជាព្រមឲ្យចៅទៅអ្នកដទៃកាន់ងាយ?

ម្តាយរបស់ខ្ញុំមិនមាត់ គាត់មិចភ្នែកប្រាប់ខ្ញុំថាគេជាឪពុកម្តាយរបស់Van ដែលគេគិតថា ចៅនេះគឺជាចៅរបស់ពួកគាត់។ ឮហើយខ្ញុំដឹងពីស្នៀតរបស់Van ដែលពោលកុហកម្តាយឪពុកគេ។

ខ្ញុំបង្ខំម៉ែថាត្រូវប្រាប់ឪពុកម្តាយគេច្បាស់ទៅថា ខ្ញុំមិនមែនជាសង្សាររបស់គេ កូននេះក៏មិនត្រូវអ្វីនឹងពួកគេដែរ។

ម្តាយខ្ញុំមិនធ្វើតាមទេ គាត់នៅមើលចៅធ្វើព្រងើយ។ ដូច្នេះហើយនៅពេលដែលខ្ញុំរួសរាន់រៀបចំសម្អាតខ្លួនរួចរាល់ហើយខ្ញុំត្រៀមចេញទៅជួបនិយាយ ស្រាប់តែខ្ញុំបានឃើញVan  នៅពីមុខគ្លីនិកជាមួយនូវអីវ៉ាន់សំពីងសំពោង។

ម្តាយឪពុករបស់គេសប្បាយចិត្តយ៉ាងខ្លាំងរៀបរាប់ប្រាប់គេអំពីសភាពសុខភាពរបស់ក្មេង។ Van  និយាយប្រាប់ខ្ញុំនៅនឹងមុខម្តាយឪពុកគេថា តើគេអាចដាក់ឈ្មោះកូននេះបានទេ?

ខ្ញុំចង់សួរវិញថាហេតុអី?

ប៉ុន្តែនៅពេលដែលចាស់ៗនៅជុំវិញទីនេះកំពុងរំភើបអំណរស្រឡាញ់ទារក ខ្ញុំមិនដឹងត្រូវឆ្លើយថាដូចម្តេច ខ្ញុំបានត្រឹមស្ងៀមសិន។

យប់នោះខ្ញុំប្រាប់Vanដែរថា ខ្ញុំដាច់ខាតត្រូវតែប្រាប់ពួកគេឲ្យបានច្បាស់ថាកូនមួយនេះមិនមែនជាចៅរបស់ពួកគេទេ ប៉ុន្តែម្តាយខ្ញុំបានពន្យល់ខ្ញុំថា ឱ្យគិតសាជាថ្មីឡើងវិញ ឱកាសមិនមែនចេះតែមាននោះទេបើមិនគិតពីខ្លួនឯងក៏ត្រូវតែអាណិតកូន។

ខ្ញុំយំទាំងសរសៃខ្មី តាមពិតខ្ញុំមិនចង់យំទេ។ ខ្ញុំប្រាប់ម្តាយជុំវិញរឿងខ្ញុំនិងVanថា បើសិនជាថ្ងៃណាមួយ ឆ្នាំណាទៅមុខទៀតយើងអាចនឹងស្រឡាញ់គ្នាឬមិន ខ្ញុំអត់សន្យាអ្វីបានទាំងអស់ ប៉ុន្តែមិនមែនពេលនេះឡើយ។

រឿងខ្ញុំនិងអេរិចអ្នកណាក៏គេដឹង ប៉ុន្តែហេតុអ្វីខ្ញុំត្រូវលាក់លៀមកុហកមនុស្សចាស់ទាំងពីរនាក់នោះរហូតដល់ថ្ងៃណាមួយគាត់ដឹងការពិត?

ម្តាយខ្ញុំយល់ព្រមឲ្យខ្ញុំនិយាយការពិតតាមត្រង់ព្រោះគាត់ក៏យល់ដែរថា ការលាក់លៀមមិនល្អនោះឡើយ។

ពេលខ្ញុំដើរកាត់មុខផ្ទះរកនឹងជួបអ្នកទាំងពីរ ស្រាប់តែខ្ញុំឮសូរពីចម្ងាយគឺVan បានសារភាពឳពុកម្តាយគេថាតាមពិតខ្ញុំនិងគេបានបែកគ្នាទៅហើយ ខ្ញុំមានអ្នកថ្មីគឺអេរិច ប៉ុន្តែស្រាប់តែខ្ញុំមានកូនមួយនេះដែលជាសំណល់របស់គេម្ល៉ោះហើយអេរិចបានខឹងហើយចាកចេញទៅអូស្រ្តាលី។

Van បានក្លាយជាមនុស្សកុហកដោយសារខ្ញុំ។

ពេលបានបែរមកឃើញខ្ញុំ គេញញឹមមករកខ្ញុំហើយដើរមកសួរនាំខ្ញុំអំពីសុខភាពខ្ញុំ។

ម្តាយឳពុកVan សុំឱ្យខ្ញុំកុំទៅណាចោលកូនប្រុសឯកោរបស់គាត់។ ខ្ញុំហួសចិត្ត ឃែតទៅVanថាខ្ញុំជំពាក់Vanច្រើនណាស់ជាតិនេះ តែខ្ញុំមិនយករឿងចុងក្រោយដែលVanបានឱ្យនេះទៀតទេ។ គេមិចភ្នែកហើយសរសេរតបខ្ញុំថា

«វណ្ណារីគិតតាមសម្រួលទៅ! រៀបការពេលណាក៏បាន ឬក៏មិនរៀបការក៏បាន មិនទទួលយកខ្ញុំក៏បានប៉ុន្តែក្មេងនេះត្រូវតែមានប៉ាខ្ញុំគឺជាប៉ារបស់គេ ខ្ញុំចុះបញ្ជីឈ្មោះ ដាក់គេជាកូនប្រុសរបស់ខ្ញុំ!»

«Van អ៊ីចឹងធ្វើអី? ហេតុអីVanមិនរកមនុស្សស្រីល្អម្នាក់!»

«វណ្ណារីជាមនុស្សស្រីល្អពេកហើយសម្រាប់ខ្ញុំ ក៏ដល់ថ្នាក់ខ្ញុំពិបាករកនរណាបានល្អជាងនេះនឹងអាចបំភ្លេចវណ្ណារីបាន!»

«មនុស្សស្រីល្អម្នាក់ដែលមានកូនដោយគ្មានឪពុក?!»

«ខ្ញុំប្រកាសតួនាទីរួចហើយថា ឪពុកក្មេងគឺនៅចំពោះមុខនេះឯង!»

មិនដឹងទេថាហេតុអីមនុស្សដែលខ្ញុំមិនស្រឡាញ់សោះ អាចធ្វើឱ្យខ្ញុំស្រក់ទឹកភ្នែកបាន? មិនយូរប៉ុន្មានរាជនិងឡែនបានមកលេងខ្ញុំ។

ជាមួយនោះពួកគេបានឆ្លៀតពន្យល់ខ្ញុំច្រើនណាស់ ឲ្យខ្ញុំយល់ព្រមទទួលយកភ័ព្វព្រេងវាសនាថ្មីមួយនេះជាមួយVan។

ទោះបីជាយ៉ាងណា រយៈពេលមួយឆ្នាំជាងបានកន្លងផុតទៅ។

គឺពេលវេលាបានកន្លងទៅយ៉ាងរហ័សតាមរបៀបដែលVanតែងតែបង្ហាញខ្លួនមកនាំកូនរបស់គេចេញដើរលេងឬទិញអីវ៉ាន់មកធ្វើឲ្យអ្នកជិតខាងលែង មានចម្ងល់ចំពោះរឿងអ្នកណាជាឪពុករបស់ក្មេង។

ប៉ុន្តែខ្ញុំមិនដែលនិយាយអំពីរឿងរៀបការ ឬសូម្បីតែទៅណាក្រៅពីរនាក់Vanនោះទេ។

ថ្ងៃទីដប់បីខែកុម្ភៈចូលដល់ មួយថ្ងៃមុនទិវានៃក្តីស្រឡាញ់Van ឈៃតសំណួមពរខ្ញុំថា តើខ្ញុំត្រូវដើរលេងព្រៃជាមួយគ្នាដែរឬទេ?

ខ្ញុំមិនឆ្លើយនោះទេ នេះជាជាចម្លើយស្រេចហើយថាខ្ញុំមិនចង់ទៅណាទាំងអស់។ ខ្ញុំក៏មិនមានអារម្មណ៍ជាយុវវ័យក្នុងការសាកល្បងបង្កើតស្នេហាថ្មីអ្វីទៀតដែរ។

មិននឹកស្មានថាព្រលឹមឡើងVanបានមកដល់រង់ចាំជាស្រេច លើសពីនោះដោយថែមមនុស្សម្នាក់មកជាមួយដែរគឺអេរិច។ ពួកគេមិនបានមកជាមួយគ្នាទេប៉ុន្តែខ្ញុំចុះមកក៏ឃើញទាំងពីរនាក់តែម្តង។

ខ្ញុំមិនដឹងថារយៈពេលជាង១០ខែនេះ អេរិចបានប្រើជីវិតនៅឯណា ការរស់នៅជាមួយនឹងកូនស្រីអ្នកមានសប្បាយចិត្តយ៉ាងណា មកដល់កម្ពុជាវិញតាមវិធីណានោះទេ ប៉ុន្តែអ្វីដែលខ្ញុំភ័យព្រួយបំផុតគឺថា តើគេអាចនឹងមកទាមទារសិទ្ធិយកកូនរបស់គេទៅអូស្ត្រាលីឬអ្វី។

ខ្ញុំទទួលពួកគេចូលមកអង្គុយជុំវិញតុមូលនៅចំហៀងផ្ទះ។ អេរិចមិនបង្ហាញអាការៈថាយកចិត្តទុកដាក់ឬមានប្រធានបទអ្វីមកទាក់ទងជាមួយក្មេងទេ ប៉ុន្តែគេបែរជាចង់បបួលខ្ញុំទៅសាងជីវិតថ្មីនៅប្រទេសអូស្ត្រាលីជាមួយគ្នា។

មនុស្សធ្លាប់ស្រឡាញ់គ្នា គ្រាន់តែកាយវិការសម្ដីប៉ុន្មានម៉ាត់ខ្ញុំអាចស្មានបានដឹងថា អេរិចមិនដាច់អាល័យចំពោះស្នេហាចាស់ជាមួយខ្ញុំ ប៉ុន្តែគេមិនឲ្យតម្លៃសំខាន់ទៅលើក្មេងនោះឡើយ។

សូម្បីតែពរក៏មិនស្និទ្ធ សូម្បីតែសួរនាំពីសុខភាពក៏គេធ្វើមិនបានមួយចំហៀងរបស់Vanផង។ ខ្ញុំបានប្រាប់អេរិចច្បាស់លាស់ថា ខ្ញុំជិតរៀបការជាមួយVan ហើយ។ ពេលនោះ Vanឮកាលណាពិតជាសប្បាយចិត្តនិងភ្ញាក់ផ្អើលជាខ្លាំង។

ខ្ញុំថែមទាំងបានប្រាប់អេរិចថាមិនអាចទទួលអង្គុយលេងបានយូរទេ ព្រោះខ្ញុំត្រូវចេញទៅបោះជំរំក្នុងព្រៃពីរនាក់ជាមួយVan ព្រោះថ្ងៃនេះជាថ្ងៃនៃក្ដីស្រឡាញ់។

កូនខ្ញុំ ខ្ញុំមិនយកទៅទេ គេនឹងនៅជាមួយម្ដាយខ្ញុំ។

ឮដូច្នេះហើយអេរិចបានចាកចេញទៅវិញបាត់ ទុកឱ្យVanនៅអង្គុយរង់ចាំខ្ញុំនៅនឹងតុដដែលនោះ។ គេអាចស្មានថា ខ្ញុំគ្រាន់តែនិយាយកុហកអេរិចឬយកគេទៅបញ្ឆើ ទីបំផុតខ្ញុំរៀបខោអាវចុះមកមែន។

ខ្ញុំពិតជាសប្បាយចិត្តចំពោះដំណើរកម្សាន្តលើកនេះ។

ប្រហែលមកពីវត្តមានអេរិចដែលធ្វើឱ្យខ្ញុំមានអារម្មណ៍ថា ហេតុអ្វីអតីតកាលគ្រប់យ៉ាងបានរលុបអស់ត្រឹមថ្ងៃនេះនិងពេលវេលានេះ។

គ្រប់យ៉ាងថ្ងៃនេះនិងថ្ងៃស្អែកគឺ វាថ្មីណាស់សម្រាប់ទាយទុក ដូច្នេះយើងជាអ្នកសាងវាឡើង។

«តស់យើងទៅ!»

ខ្ញុំហៅ Van។ គេក្រោកមកទទួលយក សាក់កាដូពីដៃខ្ញុំទៅ។

ម្ដាយខ្ញុំកាន់តែសប្បាយចិត្តទៀត គាត់ឱបចៅសម្លឹងមកពួកយើងពីចម្ងាយ។

ជាការពិត ខ្ញុំដឹងថាគ្រប់គ្នាមានសម្ពាធខ្លាំងនៅរាល់ពេលគិតដល់ការចង់ចាប់ផ្ដើមទំនាក់ទំនងថ្មីមួយសម្រាប់ជីវិត ជាពិសេសជាមួយមនុស្សដែលយើងធ្លាប់បដិសេធ ឬបដិសេធយើងពីមុនមក។ ទោះបីជាមានភាពតានតឹងបន្តិចតែយប់មិញខ្ញុំបានអានពាក្យនេះនៅលើបាច់ផ្ការបស់គេ «មុន

ពេលជួបអូន បងមិនដែលសប្បាយចិត្តទេ ពេលនេះរឿងដែលបងចង់ធ្វើបំផុត គឺធ្វើឱ្យអូនបានសប្បាយចិត្ត»

ខ្ញុំគិតចុះឡើងអំពីឃ្លាទាំងនេះ។ Van មិនដែលនិយាយពាក្យខុសគ្នាទេតាំងពីមុនដល់ឥឡូវ ហើយកាយវិការនិងការនិយាយរបស់Van ក៏ស្របគ្នាជានិច្ច។ ខ្ញុំគួរតែគិតដែរថា ហេតុអ្វីតែងតែមិនព្រមមើលគេខ្លះ? ខ្ញុំខ្មាសចំពោះកំហុសទីមួយដែលបដិសេធគេ និងកំហុសទីពីរដែលគេមកវិញនៅតែមិនព្រមពិចារណា? ខ្ញុំខ្មាសកំហុសទីបី ដែលរើសអ្នកខ្លួនត្រូវចិត្តទាំងមិនបានគិត។

ឡែនបានប្រាប់ខ្ញុំថា វាជារឿងធម្មជាតិទាំងស្រុង ឬហៅថាធម្មតាបំផុត ក្នុងការប្រើសិទ្ធិណាត់ជួបជាមួយដៃគូថ្មី ឬរចនាជីវិតថ្មីសម្រាប់ខ្លួនឯង។

ទោះជាខុសឬត្រូវ យើងមិនអាចនៅចច្រប់ជាមួយរឿងចាស់ៗឬបញ្ចប់ឱកាសខ្លួនឯងព្រោះខ្លាច ឬនៅអៀនខ្មាសដោយសារកំហុសពីមុនឡើយ។

ខ្ញុំព្យាយាមរក្សាការបើកចំហចំពោះការសាកល្បងក្នុងសកម្មភាពថ្មីនិងការចាប់ផ្ដើមនៃទំនាក់ទំនងថ្មី តែគួរតែស្រាលៗសិននិងរីករាយសិន ហើយអ្វីៗអាចស្រាលឬធ្ងន់ឡើងទៅតាមពេលវេលាទៅចុះ។

«យើងទៅនេះគឺខ្ញុំកំពុងបង្កើតឱកាសឱ្យខ្លួនខ្ញុំណា! តែនិយាយគ្នាឱ្យហើយ បើអ្វីៗមិនរីកចម្រើនទេ មិនមែនជាកំហុសVanទាំងអស់ វាជាបញ្ហារបស់ខ្ញុំខ្លួនឯង!»

ខ្ញុំនិយាយនឹងVanឱ្យច្បាស់លាស់ជាមុនខ្លាចគេរំពឹងពេកឬខ្ញុំខ្លួនឯងរំពឹងពេក។ ស្រាប់តែVan ហ៊ានលោមកកាន់ម្រាមខ្ញុំ។ ការប៉ះពាល់នេះខ្ញុំដឹងថាVan ពិតជាសប្បាយចិត្តដូចខ្ញុំដែរ។

«I will never give up on you again Vanary!»

គេនិយាយតិចៗ។

ខ្ញុំញញឹមគិត។ ពួកយើងបានបែកគ្នាច្រើនលើកច្រើនសាមកហើយទាំងមិនទាន់បានចាប់ផ្ដើម តែអារម្មណ៍នៅជំពាក់គ្នា បានលួចបង្កប់មានមក រហូតដល់ខ្ញុំនេះធ្លាប់គិតលែងជួបមុខគ្នារហូត។ ប៉ុន្តែខ្ញុំលើកនេះបែរជាគិតថា បើទោះបីជាថ្ងៃចាស់ៗមិនបានវិលត្រឡប់មកវិញប៉ុន្តែខ្ញុំនឹងធ្វើថ្ងៃថ្មីនេះឲ្យបានល្អបំផុត សម្រាប់មនុស្សម្នាក់ដែលមិនធ្លាប់Give Upចំពោះខ្ញុំ។

«បើសិនអាច ខ្ញុំមិនចង់រស់ដោយគ្មានVan ទៀតឡើយ!»

ខ្ញុំនិយាយទាំងស្រពោន ហើយធ្មេចភ្នែកគេង។

តាំងពីយូរណាស់មកហើយ មានមនុស្ស២នាក់ដែលអាចជឿទុកចិត្តគ្នាបាន ស្និទ្ធស្នាលហួសរហូតមនុស្សជាច្រើនស្មានថាពួកគេមានស្នេហា ខណៈដែលគ្រាន់តែជាការរំជួលចិត្តអារម្មណ៍នៃភាគីម្ខាង ម្ខាងទៀតគ្រាន់តែគិតថាជាមិត្តល្អបំផុតម្នាក់ប៉ុណ្ណោះ។

នៅពេលដែលមនុស្សម្នាក់ធ្វើសកម្មភាពលើមនោសញ្ចេតនា និងការទាក់ទាញភេទដោយអន្ទះអន្ទែងនិងដោយគ្មានផ្តល់ពេលវេលាគ្រប់គ្រាន់ឱ្យម្នាក់ទៀតទទួលអារម្មណ៍ដូចគ្នាអាចនាំឱ្យមានការខកចិត្ត និងខូចចិត្តរៀងខ្លួនបាន។

សេចក្តីស្រឡាញ់ពិតប្រាកដមួយ រួមបញ្ចូលការគោរព ការកោតសរសើរ ការយកចិត្តទុកដាក់ និងការមិនដាក់បន្ទុក បន្ទោសឱ្យឈឺចាប់ ឱ្យអាម៉ាស់ ឬគ្រប់ទម្រង់នៃការឡុកលើយរំលោភបំពារបំពានអារម្មណ៍ណាមួយទាំងអស់។

មនុស្សជាច្រើនធ្វើមិនបាន តែVanធ្វើបាន គេគប្បីបានទទួលរង្វាន់ជាសុភមង្គល ឯអ្នកបានសុភមង្គលពិតគឺខ្ញុំ ព្រោះខ្ញុំនឹងរស់នៅក្នុងសុភមង្គលនេះជាមួយគេ។

ពីពេលនេះទៅរៀនតាមខ្ញុំ កុំមើលរំលងនិងផ្តើមចេះឱ្យតម្លៃមនុស្សដែលមិនដែល Give Up ចំពោះយើង!